00656508

F23/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 03 / 2011
ម៉ោង (Time/Heure): 16:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រ៊ឹម ប្រធាន |
| | ចៅក្រម Motoo NOGUCHI |
| | ចៅក្រម សោម សិរីវុឌ្ឍ |
| | ចៅក្រម Agnieszka KLONOWIECKA-MILART |
| | ចៅក្រម ស៊ិន រិទ្ធ |
| | ចៅក្រម Chandra Nihal Jayasinghe |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១សុំលុប វិធានការការពារ



E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

00656509

០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ. F23/1

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew T. CAYLEY

**ជនជាប់ចោទ**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រ៊ីនណា

Karim KHAN

Alain WERNER

Brianne McGONIGLE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គីមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN

Annie DELAHAIE

Philippe CANONNE

Elizabeth RABESANDRATANA

Fabienne TRUSSES-NAPROUS

Christine MARTINEAU

សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១សុំលុប

វិធានការការពារខ្លួន។

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**"):

**បានទទួល**នូវសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំដកវិធានការការពាររបស់ដើមបណ្តឹរដ្ឋប្បវេណីE2/62" ("**សំណើសុំ**")[1] ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ("**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**") ។

**រំលឹកឡើងវិញថា** នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបង្គាប់មិនឲ្យបង្ហាញអត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីE2/62 និងព័ត៏មានស្តីពីអត្តសញ្ញាណជាសាធារណៈ ឡើយ[2] ("**វិធានការការពារ**")។

[1] ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១, F23.

[2] សេចក្តីសម្រេចស្តីពីវិធានការការពារខ្លួនសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី E2/62 និង E2/89 និងសាក្សីKW-10 និង KW-24, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧, E135, ទំព័រ 3, កថាខណ្ឌ ៤។ ទំព័រ៥ អង្គជំនុំជម្រះសាលាដំបូង បង្គាប់ដូចខាងក្រោយ:

(ក) ថាភាគីក្នុងដំណើរការនីតិវិធី ត្រូវហៅឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនេះថាE2/62។

(ខ) ថាអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីE2/62 និងព័ត៌មានផ្សេងៗដែលអាចបង្ហាញពីអត្តសញ្ញាណរបស់គាត់ជាភាគីក្នុងដំណើរការនីតិវិធី មិនបង្ហាញជាសារណៈ ឬ តាមប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗឡើង។

(ខ) ថា ប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យានានា ក្នុងការអនុញ្ញាតនូវការចូលរួមពីចំងាយ ឬ ការកែសំលេងនៃដើមបណ្តឹងរដ្ឋប្បវេណី E2/62 និងបិទបាំងរូបភាពនានា ប្រសិនបើជនជាប់ចោទ ឬ ជនត្រូវចោទនៅចំពោះមុខអវតក ធ្វើការស្នើសុំនៅពេលប្រឈមមុខជាមួយ ដើមបណ្តឹងរដ្ឋប្បវេណី E2/62។

**កត់សំគាល់ឃើញថា** សំណើនេះស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល លុបចោលវិធានការការពារទាំងនេះចេញ[3]។

**កត់សំគាល់ឃើញថា** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ផ្តល់សំអាងហេតុលើសំណើរបស់ខ្លួនដូចខាងក្រោមៈ ក) ដើមបណ្តឹងរដ្ឋប្បវេណី E2/62 ដែលជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ដែល បានបោះបង់ឋានៈការការពារក្នុងសំណុំរឿងនេះ និង ខ) នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ តាមរយៈអន្តរការីរបស់ខ្លួន បានធ្វើការទំនាក់ទំនងដើមបណ្តឹងរដ្ឋប្បវេណីE2/62 ហើយ គាត់បានយល់ស្របដោយសុំឱ្យដកនូវវិធានការការពារចេញ ក្នុងគោលបំណងនៃសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០១ និងសំរាប់ដំណើរការនីតិវិធីផ្សេងៗទៀតនៃសំណុំរឿង០០១។

**រំលឹកឡើងវិញថា** មាត្រា៤.១ នៃសេចក្តីណែនាំអនុវត្តស្តីពីវិធានការការ[4](“សេចក្តីណែនាំអនុវត្ត”)ដែលចែងថា “នៅពេលដែលត្រូវបានបង្គាប់ដោយតុលាការ វិធានការការពារ ត្រូវបន្តអនុវត្ត ដូចគ្នាក្នុងគ្រប់កិច្ចនីតិវិធីទាំងមូលក្នុងសំណុំរឿងដែលពាក់ព័ន្ធ និងទាក់ទងទៅនឹង នីតិវិធីដទៃទៀតដែលនៅចំពោះមុខតុលាការ និង ត្រូវបន្តអនុវត្តរហូតទាល់តែវិធានការការពារ ត្រូវបានលុបចោល ឬ កែប្រែដោយអនុលោមតាមបញ្ញត្តិនៃសេចក្តីណែនាំអនុវត្ត”។

---

[3] សំណើសុំកថាខណ្ឌ១។

[4] សេចក្តីណែនាំអនុវត្ត ECCC/03/2007/ វិសោធនកម្មទី១។



* E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME

**រំលឹកឡើងវិញថា** មាត្រា៤.៤ នៃសេចក្តីណែនាំអនុវត្តចែងថា "នៅក្នុងការចេញដីកាកែប្រែវិធានការការពារខ្លួន នីតិវិធីនៃមាត្រា២នៃសេចក្តីណែនាំអនុវត្តនេះ ត្រូវតែយកមកអនុវត្ត។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលទទួលបន្ទុក ត្រូវស្វែងរកការយល់ព្រមពីបុគ្គលដែលដាក់ពាក្យសុំលុប ឬ ប្តូរនូវវិធានការការពារខ្លួននេះ"។

**បានពិគ្រោះ**ជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ("WESU") ដោយយោងតាមមាត្រា២.៣ នៃសេចក្តីណែនាំអនុវត្ត ថាតើស្នើសុំលុបចោលវិធានការការពារនេះ ដែរឬទេ។

**កត់សំគាល់ឃើញ** ថាសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានទទួលការយល់ព្រមរបស់ដើមបណ្តឹងរដ្ឋប្បវេណីE2/62 សុំលុបចោលវិធានការការពារ។

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទៈ៖**

**លុបចោល** វិធានាការការពារខ្លួនសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីE2/62ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ដាក់លេខឯកសារ E135 ក្នុងសំណុំរឿង០០១។

**បង្គាប់** ផ្នែកគ្រប់គ្រងតុលាការ ធ្វើចំណាត់ថ្នាក់ឯកសារដូចខាងក្រោមរដ្ឋប្បវេណីE2/62 ចេញពីចំណាត់ថ្នាក់សម្ងាត់ទៅជាសាធារណៈ និងជូនដំណឹងដល់ភាគីបណ្តឹងសាទុក្ខនានានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០១។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

| ឈ្មោះឯកសារ | លេខឯកសារ | KH ERN | EN ERN |
|---|---|---|---|
| សំណើសុំ | E2/62 | 00279960-00279965 (6 pages) | |
| លិខិតបញ្ជាក់ | F2/3.2.1 | 00651489-00651489 (1 page) | 00651488-00651488 (1 page) |
| លិខិតបញ្ជាក់ | F2/3.2.2 | 00651491-00651491 (1 page) | 00651490-00651490 (1 page) |
| លិខិតបញ្ជាក់ | F2/3.2.3 | 00651493-00651493 (1 page) | 00651492-00651492 (1 page) |

**សម្រេច** ពិគ្រោះជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ (WESU) តាមពេលសមស្របលើការដាក់ឯកសារដទៃទៀតពាក់ព័ន្ធទៅនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីE2/62 ក្នុងការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញពីសម្ងាត់ទៅជាសាធារណៈ។

**បង្គាប់** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/62 ចាប់ពីពេលនោះតទៅនឹងត្រូវបានបង្ហាញឈ្មោះ ជាមួយនឹង លេខឯកសារយោងពាក់ព័ន្ធនៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណីចាំបាច់។ និង

**បង្គាប់** ផ្នែកគ្រប់គ្រងតុលាការ ធ្វើការជូនដំណឹងសេចក្តីសម្រេចនេះ ដល់ភាគីទាំងអស់ ក្នុងសំណុំរឿង ០០១ និង០០២ អង្គភាពគាំពារជនរងគ្រោះ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងការិយាល័យសហចៅក្រមស៊ើបអង្កេតជាដើម។

រាជធានីភ្នំពេញ ថ្ងៃទី២៥ មីនា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C * SUPREME COURT CHAMBRE DE LA COUR

**គង់ ស្រ៊ឹម**